ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

## វិធីសាស្ត្រកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

ធនាគារជាតិនៃកម្ពុជា មានតួនាទីរៀបចំ និងកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកនៅរៀងរាល់ថ្ងៃធ្វើការ និងដាក់ផ្សព្វផ្សាយនៅម៉ោង ៥:៣០ នាទីរសៀល លើប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា សម្រាប់ប្រសិទ្ធភាពប្រើប្រាស់នៅថ្ងៃធ្វើការបន្ទាប់។ ដើម្បីធានាថាអត្រាប្តូរប្រាក់ផ្លូវការមានភាពច្បាស់លាស់ តម្លាភាព សុក្រិតភាព និងឆ្លុះបញ្ចាំងពីអត្រាប្តូរប្រាក់នៅលើទីផ្សារ

អត្រាប្តូរប្រាក់ផ្លូវការត្រូវបានគណនាដោយផ្អែកតាមវិធីសាស្ត្រចំនួន២ដូចខាងក្រោម៖

**១. ករណីប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារធម្មតា:** ប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារតាមរយៈប្រព័ន្ធ NBCP FX Platform មានទំហំទឹកប្រាក់ស្មើឬលើស ៥លានដុល្លារអាមេរិក និងមានគ្រឹះស្ថានធនាគារចូលរួមចាប់ពី ៣គ្រឹះស្ថាន៖ ***អត្រាប្តូរប្រាក់ផ្លូវការ ត្រូវគណនាផ្អែកលើអត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូរ (The Volume Weighted Average Exchange Rate) ក្នុងទីផ្សារអន្តរធនាគារដែលបានបញ្ចប់ដោយជោគជ័យនៅលើប្រព័ន្ធ NBCP FX Platform (ក)។***

**២. ករណីប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារមានកម្រិត:** ប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារតាមរយៈប្រព័ន្ធ NBCP FX Platform មានទំហំទឹកប្រាក់តិចជាង ៥លានដុល្លារអាមេរិក និង/ឬចំនួនគ្រឹះស្ថានធនាគារចូលរួមតិចជាង ៣គ្រឹះស្ថាន៖ ***អត្រាប្តូរប្រាក់ផ្លូវការ ត្រូវគណនាផ្អែកលើអត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូរក្នុងទីផ្សារអន្តរធនាគារដែលបានបញ្ចប់ដោយជោគជ័យនៅលើប្រព័ន្ធ NBCP FX Platform (ក) និងអត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូររវាងគ្រឹះស្ថានធនាគារ និងអតិថិជនដែលមានទំហំចាប់ពី ១០០លានរៀលឡើងទៅក្នុងមួយប្រតិបត្តិការ (ខ)*។***

**រូបមន្តគណនា៖**

**អត្រាប្តូរប្រាក់ផ្លូវការ = (0,៥ x "ក") + (0,៥ x "ខ")**

* **Outlier Rule;** វិធាននេះត្រូវបានអនុវត្តក្នុងគោលបំណងធានាថា រាល់អត្រាប្តូរប្រាក់របស់ប្រតិបត្តិការទិញ-លក់ដែលមិនមានភាពប្រក្រតី និងខុសពីស្ថានភាពជាក់ស្តែងនៃទីផ្សារប្តូរប្រាក់ ត្រូវបានដកចេញពីការគណនាអត្រាប្តូរប្រាក់ផ្លូវការ។ ការគណនាអត្រាប្តូរប្រាក់ផ្លូវការ (OER) នឹងដកចេញនូវប្រតិបត្តិការដែលមានអត្រាប្តូរប្រាក់ដែលមានកម្រិតខ្ពស់បំផុត និងទាបបំផុតចំនួន ១ ភាគរយ (1% Percentile)



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- **"ក"** អត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូរក្នុងទីផ្សារអន្តរធនាគារដែលបាន បញ្ចប់ដោយជោគជ័យនៅលើប្រព័ន្ធ NBCP FX Platform

- **"ខ"** អត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូររវាងគ្រឹះស្ថានធនាគារ និងអតិថិជន ដែលមានទំហំចាប់ពី ១០០លានរៀលឡើងទៅក្នុងមួយប្រតិបត្តិការ។

**៣. ករណីមិនមានប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារអន្តរធនាគារៈ** ករណីមិនមានប្រតិបត្តិការទិញ-លក់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកនៅក្នុងប្រព័ន្ធ NBCP FX Platform៖ *អត្រាប្តូរប្រាក់ផ្លូវការ ត្រូវគណនាដោយប្រើអត្រាប្តូរប្រាក់មធ្យមភាគសមតានៃទំហំប្រតិបត្តិការជួញដូររវាង គ្រឹះស្ថានធនាគារ និងអតិថិជនដែលមានទំហំចាប់ពី ១០០លានរៀលឡើងទៅក្នុងមួយប្រតិបត្តិការ (ខ)* *។